ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ...១០...សសរ.

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួង សម្រាប់រៀបចំផែនការសកម្មភាព និង តាមដានការអនុវត្តការងារកៀរគរ និង គ្រប់គ្រងចំណូលពីប្រេង ឧស្ម័ន និង ធនធានរ៉ែដទៃទៀត

៚✤៚

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៧ ស្តីពីការបង្កើតគណៈកម្មាធិការសម្រាប់គោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

www.pheakdeylaw.com

-បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០៧ ស្តីពីការកែសម្រួលការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-យោងតាមតម្រូវការក្នុងការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## សម្រេច

**ប្រការ ១:** បង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួង ដែលស្ថិតក្រោមក្របខ័ណ្ឌនៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីរៀបចំផែនការសកម្មភាពការងារដែលពាក់ព័ន្ធទៅនឹងការងារគៀរគរ និង គ្រប់គ្រងចំណូលពីប្រេង ឧស្ម័ន និង ធនធានរ៉ែដទៃទៀត ។

**ប្រការ ២:** ក្រុមការងារនេះមានសមាសភាព ដូចខាងក្រោម :

| | |
|---|---|
| – អគ្គលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ប្រធាន |
| – តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| – តំណាងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | សមាជិក |
| – តំណាងក្រសួងផែនការ | សមាជិក |
| – តំណាងអាជ្ញាធរប្រេងកាតជាតិកម្ពុជា | សមាជិក |
| – តំណាងក្រសួងបរិស្ថាន | សមាជិក |
| – តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| – តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| – តំណាងក្រសួងយុត្តិធម៌ | សមាជិក |
| – តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | សមាជិក |
| – តំណាងក្រសួងមហាផ្ទៃ | សមាជិក |

**ប្រការ ៣:** ក្រុមការងារនេះមានភារកិច្ច និង តួនាទី ដូចខាងក្រោម :

- រៀបចំផែនការសកម្មភាព ដើម្បីគៀរគរ និង គ្រប់គ្រងចំណូលពីប្រេង ឧស្ម័ន និង ធនធានរ៉ែដទៃទៀត
- តាមដាន និង វាយតម្លៃការអនុវត្តផែនការសកម្មភាព
- សិក្សា និង ប្រមូលផ្តុំយោបល់ពីអ្នកជំនាញការ និង បទពិសោធន៍ទាំងឡាយនៅបណ្តាប្រទេសផលិតប្រេងផ្សេងៗ ស្នើឡើងនូវអនុសាសន៍សម្រាប់កែលម្អក្របខ័ណ្ឌគតិយុត្ត យន្តការស្ថាប័ន និង ការកសាង

www.pheakdeylaw.com

សមត្ថភាព ដើម្បីគោលដៅនៃការគ្រប់គ្រងចំណូលពីប្រេង ឧស្ម័ន និង ធនធានរ៉ែដទៃទៀត ប្រកបដោយ ប្រសិទ្ធភាព តម្លាភាព និង គណនេយ្យភាព

- ពិនិត្យ និង តាមដានការអនុវត្តរបបសារពើពន្ធ ដូចជា រចនាសម្ព័ន្ធ និង គោលនយោបាយពន្ធដារ គោលនយោបាយតម្លាភាព និង ការគ្រប់គ្រងចំណូល ហើយស្នើឡើងនូវអនុសាសន៍ ដើម្បីកែលម្អ
- ពិនិត្យ និង ផ្តល់យោបល់លើកិច្ចព្រមព្រៀង និង កិច្ចសន្យា ពាក់ព័ន្ធនឹងការរុករក និង អាជីវកម្មប្រេង ឧស្ម័ន និង ធនធានរ៉ែដទៃទៀត ពិសេសលើទិដ្ឋភាពទាំងឡាយ ដែលពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុ សាធារណៈ
- សិក្សាពីតម្រូវការស្ថាប័នសម្រាប់ការងារកៀរគរ ចាត់ចែង និង គ្រប់គ្រងចំណូលប្រេង ឧស្ម័ន និង ធនធានរ៉ែដទៃទៀត
- ពិនិត្យ និង ផ្តល់អនុសាសន៍អំពីការរៀបចំរបាយការណ៍ យន្តការអនុវត្ត គោលការណ៍គណនេយ្យ សវនកម្ម និង ការងារសម្របសម្រួល
- សិក្សា និង កំណត់ពីប៉ារ៉ាម៉ែត្រដែលត្រូវរាយការណ៍ និង ត្រូវផ្សព្វផ្សាយជាសាធារណៈ ព្រមទាំង វិធីសាស្ត្រក្នុងការផ្សព្វផ្សាយ
- សិក្សា និង កំណត់អំពីនិយមន័យប្រភេទចំណូលប្រេង និង ចំណូលក្រៅពីប្រេង ឧស្ម័ន និង ធនធានរ៉ែ ដទៃទៀត
- វាយតម្លៃពីតម្រូវការកសាងសមត្ថភាពចាំបាច់សម្រាប់ក្រុមការងារនេះ និង ស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្ត ការងារអោយមានប្រសិទ្ធភាព ។

**ប្រការ ៤:** ក្រុមការងារបច្ចេកទេសអន្តរក្រសួងនេះនឹងត្រូវកោះប្រជុំជាទៀងទាត់ តាមការអញ្ជើញរបស់ប្រធាន ក្រុមការងារ និង រាយការណ៍ជូនជាប្រចាំដល់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**ប្រការ ៥:** ក្រុមការងារមានសិទ្ធិអញ្ជើញមន្ត្រីជំនាញចាប់ពីថ្នាក់អគ្គនាយកចុះ ពីក្រសួងស្ថាប័នដែលមានការពាក់ព័ន្ធ ដើម្បីចូលរួមប្រជុំតាមការចាំបាច់ ។

**ប្រការ ៦:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួង យុត្តិធម៌ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួង

www.pheakdeylaw.com

មហាផ្ទៃ អគ្គនាយកអាជ្ញាធរប្រេងកាតជាតិកម្ពុជា និង អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***ចម្លងជូនៈ***

- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ដូចប្រការ ៦*
- *ឯកសារ-កាលប្បវត្តិ*

www.pheakdeylaw.com